# ខ្មែរជិតធ្លាក់ខ្លួន



ព្រះមហាថេរ ឥន្ទបញ្ញោ ឯិន គេន
អតីតព្រះមេគណរាជធានីភ្នំពេញ កម្ពុជា
វត្តពោធិវង្ស ប្រទេសបារាំង
youtube.com/user/Khmerbuddhist

ខ្មែរជិតធ្លាក់ខ្លួនខ្ញុំគេហើយ
បងប្អូនខ្មែរអើយគិតយ៉ាងម៉េច
អ្នកដឹកនាំខ្លះបែបលោកភ្លេច
ព្រោះចង់ធ្វើស្តេចធ្វើនាយក...។
ស្តេចខ្លះលោកមិនបានភ្លេចទេ
តែមន្ត្រីខ្មែរខ្លះគម្រក់
ព្រោះតែចង់បានធ្វើនាយក
សុខចិត្តព្រមលក់ដីឱ្យយួន។
ឯករាជ្យមានតែសម្បកក្រៅ
ខ្មែរខ្លះល្ងង់ខ្លៅមិនដឹងខ្លួន
នឹកស្មានថាខ្មែរនៅមាំមួន
តែពិតពួកយួនក្តាប់ពីលើ។
អ្នកខ្លះសប្បាយនឹងបុណ្យស័ក្តិ
បានមាសបានប្រាក់មិនចង់រើ
នឹកស្មានថាខ្លួនឯងគ្រាន់បើ
មិនដឹងជាភ្លើកញ្ជះគេ។
បើយើងសំងំតាមពួកនេះ
យើងមិនខំរិះរើខ្លួនទេ
ជាតិយើងនឹងទៅជាខ្ញុំគេ
ថ្ងៃមុខងាករវលែងបានហើយ។
គេភ្ជាក់រើខ្លួនគ្រប់តែគ្នា
ម្តេចកម្ពុជានៅកន្តើយ
បើអ្នកមិនព្រមរើខ្លួនហើយ
តើអ្នកណាឡើយរើជួសអ្នក។
រស់នៅខ្ញុំគេគ្មានតម្លៃ
បើទុកជាក្ស័យថ្លៃអនគ្ឃ
បូជាជូនជាតិដោយក្តីស្ម័គ្រ
ជាតិចងចាំជាក់ទុកមិនភ្លេច។
ជាតិណាក៏គេលះបង់ដែរ
ម្តេចយើងជាតិខ្មែរបែរកលគេច
តើឱ្យគេយល់ថាយ៉ាងម៉េច
ទុកខ្មែរជាដុំពេជ្រ ឬដុំក្រួស។
ដូចនេះជាតិខ្មែរទាំងប្រុសស្រី
អ្នកស្រុកភូមិក្តី ឬអ្នកបួស
កុំទុកឱ្យពេលវាដើរហួស
យើងគ្មានអ្វីជួសជុលបានឡើយ។
ភ្ញាក់ឡើងក្រោកឡើងរើបម្រះ
ទាំងក្មេងទាំងចាស់កុំកន្តើយ
រំដោះជាតិយើងរួចផុតហើយ
ទុក្ខខ្មែរបានស្បើយសុខសាន្តហោង៕

ដកស្រង់ចេញពីសៀវភៅ ទសពិធរាជធម៌ រៀបរៀងដោយព្រះភិក្ខុ ឥន្ទបញ្ញោ ឯិន គេន នាឆ្នាំរកា ព.ស.២៥៤៩? គ.ស.២០០៥? វត្តពោធិវង្ស ប្រទេសបារាំង

ផ្សាយឡើងវិញដោយទូរទស្សន៍ Templenews.org
នាឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ គ.ស.២០១១